# អរិយធម៌ម៉ាយ៉ា ( Maya Civilization)

ប្រវត្តិសាស្ត្រនៃអរិយធម៌ម៉ាយ៉ា គឺជាប្រធានបទមួយដែលមានការជជែកគ្នាយ៉ាងច្រើន ក្នុងចំណោមអ្នកស្រាវជ្រាវមួយចំនួនដូចជា ប្រវត្តិវិទូ នរវិទូ និងបុរាណវិទូជាដើម ដែលបាន សិក្សាស្រាវជ្រាវពិសេសក្នុងតំបន់អាមេរិកកណ្ដាល។ ដ្បិតវិសាលភាពនៃអរិយធម៌នេះ គឺ មានការរីកចម្រើនខ្លាំង និងបានបន្សល់នៅស្ថានីយ៍បុរាណជាច្រើននៅតាមបណ្ដាប្រទេស ក្នុងតំបន់អាមេរិកកណ្ដាល។

ម៉ាយ៉ា គឺជាជនជាតិដើមដែលរស់នៅក្នុងព្រៃត្រូពិកក្នុងតំបន់អាមេរិកកណ្ដាល និង ត្រូវបានអ្នកស្រាវជ្រាវស្គាល់ថា ម៉ាយ៉ាជាអរិយធម៌ចំណាស់ទី២ក្នុងចំណោមអរិយធម៌ មេសូអាមេរិក បន្ទាប់ពីអរិយធម៌អូលមេក។[១] វិសាលភាពទឹកដីនៃអរិយធម៌នេះមានការរីក ចម្រើននៅតំបន់អាមេរិកកណ្ដាលដែលបច្ចុប្បន្នជាប្រទេសម៉ិកស៊ិកូ ហ្គាតេម៉ាឡា បេលីហ្ស ហុងឌូរ៉ាស និងអែលសាល់វ៉ាឌ័រ (រូបលេខ១)។[២]

ក្នុងប្រវត្តិសាស្ត្រនៃអរិយធម៌ម៉ាយ៉ា អ្នកស្រាវជ្រាវបានបែងចែកចេញជាបីសម័យធំៗ គឺសម័យ Pre-Classic, Classic និង Post-Classic។ សម័យ Pre-Classic(១០០០មុនគ.ស រហូត ដល់ ឆ្នាំ២៥០នៃគ.ស. )ដែលជាសម័យកាលនៃការកកើតវប្បធម៌ និងអរិយធម៌ម៉ាយ៉ានៅ ក្នុងតំបន់អាមេរិកកណ្ដាល។ ក្នុងសម័យកាលនោះ ប្រជាជនម៉ាយ៉ា គឺជាសង្គមដែលរស់ នៅតាមបែបការបរបាញ់សត្វ ចាប់សត្វព្រៃធ្វើជាចំណីអាហារ (Hunter- gatherer)។[៣] រីឯ សម័យ Classic (ឆ្នាំ២៥០គ.ស. រហូតដល់ឆ្នាំ៩០០គ.ស.) ត្រូវបានអ្នកស្រាវជ្រាវស្គាល់ថា ជាសម័យនៃការរីកចម្រើនសំណង់ សិល្បៈ វប្បធម៌ និងការពង្រីកទឹកដីកាន់តែធំរហូត ដល់ក្លាយជាអាណាចក្រម៉ាយ៉ា។[៤] សម័យ Post Classic ជាសម័យកាលដែលបន្តពីសម័យ

---

[១] https://ams.com.kh/khmercivilization/?p=14942

[២] Robert Sharer 2006

[៣] Robert Sharer 2006

[៤] https://www.history.com/topics/ancient-americas/maya

អត្ថបទដោយ៖ អេង តុលា

Classic រហូតដល់ដើមស.វ.ទី១៦ ( ឆ្នាំ១៥៣៩នៃគ.ស.) នៅពេលដែលពួកអេស្ប៉ាញបាន មកដល់តំបន់អាមេរិកកណ្តាល។[៥]

ចាប់ពីតំបន់ព្រៃត្រូពិកទឹកភ្លៀងដែលស្ថិតនៅភាគពាយ័ព្យ នៃប្រទេសហ្គាតេម៉ាឡា បេលីហ្ស និងតំបន់ឈីប៉ាស នៃប្រទេសម៉ិកស៊ិកូ ដោយអ្នកស្រាវជ្រាវបានបង្ហាញថាជាតំបន់ស្នូលសំខាន់ នៃអាណាចក្រម៉ាយ៉ាក្នុងសម័យ Classic។[៦] សម័យ Classic គឺជាសម័យកាលដែលអរិយធម៌ម៉ាយ៉ារុងរឿងខ្លាំង។ នៅអំឡុងស.វទី១៩ តាមរយៈការស្រាវជ្រាវរបស់អ្នកភូមិវិទូ និងបុរាណវិទូលើទីក្រុងបុរាណរបស់អរិយធម៌ម៉ាយ៉ា បានរកឃើញទីតាំងប្រហែល ៤០កន្លែង ក្នុងចំណោមនោះមាន៦ទីតាំងដែលអ្នកស្រាវជ្រាវបង្ហាញថាជាទីក្រុងសំខាន់ៗ នៃអាណាចក្រម៉ាយ៉ា ក្នុងនោះរួមមានដូចជានៅស្ថានីយ៍ Copan (Honduras), Calakmul (Mexico), Palenque (Mexico), Yucatán (Mexico), Quirigua (Guatemala) និង Tikal (Guatemala) (រូបលេខ២-៧)។[៧] បច្ចុប្បន្នទីតាំងទាំង៦នោះ គឺស្ថិតនៅប្រទេសផ្សេងៗគ្នា ពោលមាននៅប្រទេសម៉ិកស៊ិកូចំនួន៣ទីតាំង ហ្គាតេម៉ាឡាចំនួន២ទីតាំង និងនៅហុងឌូរ៉ាស ចំនួន១ទីតាំង។

ការរៀបចំក្រុងនៃអរិយធម៌ម៉ាយ៉ា គឺជាការរៀបចំជាបណ្តុំនៃសំណង់ ដោយសំណង់គោលនោះ គឺជាប្រាសាទពីរ៉ាមីតដែលសម្រាប់ការគោរពដល់ព្រះក្នុងអរិយធម៌ម៉ាយ៉ាបុរាណ។ លើសពីនេះតាមរយៈសំណង់ សិល្បៈ និងស្ថាបត្យកម្ម អ្នកស្រាវជ្រាវបានដឹងថាប្រជាជនម៉ាយ៉ាមានចំណេះដឹងខាងផ្នែក គណិតវិទ្យា តារាសាស្ត្រ ប្រតិទិន និងការរៀបចំក្រុង។[៨] អ្នកស្រាវជ្រាវក៏បានដឹងថា នៅសម័យ Classic ការផលិតកសិកម្មគឺជាកត្តាយ៉ាងសំខាន់ក្នុងការរីកចម្រើនអរិយធម៌ (រូបលេខ២៨)។[៩]

---

[៥] https://www.history.com/topics/ancient-americas/maya

[៦] https://www.bbc.com/travel/article/20120326-through-mexicos-mayan-heartland

[៧] ស្ថានីយ៍ទាំងអស់នោះ អាចស្វែងរកបានលើវេបសាយរបស់ https://en.unesco.org

[៨] https://www.history.com/topics/ancient-americas/maya

[៩] E. Andersson 2018, P. 9

អត្ថបទដោយ៖ អេង តុលា

ប្រហែលនៅចុងស.វ.ទី១០ បណ្តាទីក្រុងនៃអរិយធម៌ម៉ាយ៉ាត្រូវបានបោះបង់ចោល។ នៅដើមស.វ.ទី១៦ មានការមកដល់នូវជនជាតិអេស្ប៉ាញក្នុងតំបន់អាមេរិកកណ្តាល។ អ្នកស្រាវជ្រាវពុំដឹងអំពីមូលហេតុ នៃការដួលរលំនៃអាណាចក្រម៉ាយ៉ានៅឡើយ ប៉ុន្តែប្រហែលមកពីការមកដល់នូវជនជាតិអេស្ប៉ាញពីឈ្លានពានគ្រប់គ្រង់លើអាណាចក្រម៉ាយ៉ា និងបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងតំបន់។[១០]

តាមរយៈសំណង់ស្ថាបត្យកម្ម និងសិល្បៈដែលបានបន្សល់ពីអរិយធម៌ម៉ាយ៉ា អ្នកស្រាវ-ជ្រាវបានបង្ហាញថា អរិយធម៌នៃអាណាចក្រម៉ាយ៉ាមានឥទ្ធិពលខ្លាំងក្លា រុងរឿងជាងគេនៅតំបន់អាមេរិកកណ្តាល និងបង្ហាញថាជនជាតិម៉ាយ៉ាបានមកតាំងទីរស់នៅក្នុងអាមេរិកកណ្តាលប្រមាណជាង១៥០០ឆ្នាំមុនគ.ស.[១១] និងបានក្លាយជាអាណាចក្រម៉ាយ៉ានៅសតវត្សទី៦នៃគ.ស.។[១២]




រូបលេខ១៖ ផែនទីនៃវិសាលភាពអាណាចក្រម៉ាយ៉ាបុរាណ
ប្រភព៖ https://www.history.com

[១០] https://www.history.com/news/why-did-the-maya-abandon-their-cities
[១១] https://www.britannica.com/topic/Maya-people
[១២] https://www.history.com/topics/ancient-americas/maya

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៤៖ ទីក្រុង Copan នៅHonduras
ប្រភព៖ Google



រូបលេខ២៣៖ ទីក្រុង Calakmul នៅMexico

ប្រភព៖ Google

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៨៖ ទីក្រុង Palenque នៅMexico

ប្រភព៖ Google



រូបលេខ២៩៖ ទីក្រុង Yucatán(Mexico)

ប្រភព៖ Petites bullies d’ailleurs



រូបលេខ៦៖ ទីក្រុង Quirigua(Guatemala)

ប្រភព៖ Google



រូបលេខ៧៖ ទីក្រុង Tikal (Guatemala)

ប្រភព៖ https://www.history.com

អត្ថបទដោយ៖ អេង តុលា



រូបលេខ៨៖ ប្រតិទិនដែលម៉ាយ៉ាបង្កើតឡើងដោយការប្រើប្រព័ន្ធគណិតវិទ្យា
ប្រភព៖ Google



រូបលេខ៩៖ រូបចម្លាក់ក្នុងអរិយធម៌ម៉ាយ៉ា
ប្រភព៖ https://www.netmuseum.org

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

Robert Sharer
2006 Who were the maya?
E.Robert Sharer
20018 A Case Study of the Regional Spatial Differences in the Mayan Natural- and Urban Landscapes
Website
https://ams.com.kh/khmercivilization/?p=14942
https://www.history.com/topics/ancient-americas/maya
https://www.bbc.com/travel/article/20120326-through-mexicos-mayan-heartland
https://en.unesco.org
https://www.history.com/news/why-did-the-maya-abandon-their-cities
https://www.britannica.com/topic/Maya-people

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា